ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី ឆ្នាំទី ១១ លេខ ៦

# ព្រឹត្តិបត្រព័ត៌មាន

## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

# សកម្មភាព ការងារ

ECOSOCC



ក ស វ

Work Activities

ប្រចាំខែមិថុនា ឆ្នាំ២០១៨



# មាតិកា


| ល.រ បរិយាយ | លេខទំព័រ |
|---|---|
| I- កិច្ចប្រជុំជំនាញបច្ចេកទេស | |
| - សេចក្តីព្រាងសារាចរស្តីពីការរៀបចំទិវាមនុស្សចាស់កម្ពុជា និងទិវាមនុស្សចាស់អន្តរជាតិឆ្នាំ២០១៨ និងសារលិខិតរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសទិវាមនុស្សចាស់កម្ពុជា និងទិវាមនុស្សចាស់អន្តរជាតិ ថ្ងៃទី១ ខែតុលា ឆ្នាំ២០១៨ | ១-២ |
| II- សកម្មភាពការងាររបស់ក្រុមវាយតម្លៃលើផលប៉ះពាល់លិខិតបទដ្ឋានគតិយុត្ត( ក្រុម RIA ) | |
| ១- សិក្ខាសាលាផ្សព្វផ្សាយស្តីពីការវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត នៅក្រសួងកសិកម្ម រុក្ខប្រមាញ់ និងនេសាទ | ៣-៥ |
| ២- សិក្ខាសាលាផ្សព្វផ្សាយស្តីពីការវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត នៅក្រសួងសុខាភិបាល | ៦-៧ |
| III- កិច្ចប្រជុំស្តីពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជាប្រចាំខែឧសភា ឆ្នាំ២០១៨ | ៨-១៥ |
| IV- សកម្មភាពដទៃទៀតរបស់ ឯកឧត្តម ទេសរដ្ឋមន្ត្រី **យឹម ណុលឡា** ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែមិថុនា ឆ្នាំ២០១៨ | ១៦-១៩ |

# សេចក្តីព្រាងសារាចរស្តីពី

## ការរៀបចំទិវាមនុស្សចាស់កម្ពុជា និងទិវាមនុស្សចាស់អន្តរជាតិ ឆ្នាំ២០១៨ និងសារលិខិតរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសទិវាមនុស្សចាស់កម្ពុជា និងទិវាមនុស្សចាស់អន្តរជាតិ ថ្ងៃទី១ ខែតុលា ឆ្នាំ២០១៨



កាលពីថ្ងៃព្រហស្បតិ៍១២កើត ខែពិសាខ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦១ ត្រូវនឹងថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០១៨ នៅទីស្តីការគណៈរដ្ឋមន្ត្រី មានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **ឆយ អូន** សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECO-SOCC) និង ឯកឧត្តម **ផៃ សុខខេង** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើសេចក្តីព្រាងសារាចរស្តីពីការ រៀបចំទិវាមនុស្សចាស់កម្ពុជា និងទិវាមនុស្សចាស់អន្តរជាតិឆ្នាំ២០១៨ និងសារលិខិតរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាក្នុងឱកាសទិវាមនុស្សចាស់កម្ពុជា និងទិវាមនុស្សចាស់អន្តរជាតិ ថ្ងៃទី១ ខែតុលា ឆ្នាំ២០១៨ ដោយមានការអញ្ជើញចូលរួមពី សមាជិកនិងមន្ត្រីនៃក.ស.វ. សមាជិកនិងមន្ត្រីនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល មន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី និងតំណាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាបានរៀបចំសេចក្តីព្រាងសារាចរស្តីពី ការរៀបចំទិវាមនុស្សចាស់កម្ពុជា និងទិវាមនុស្សចាស់អន្តរជាតិឆ្នាំ២០១៨ និងសារលិខិតរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសទិវាមនុស្សចាស់កម្ពុជា និងទិវាមនុស្សចាស់អន្តរជាតិ ថ្ងៃទី១ ខែតុលា ឆ្នាំ២០១៨ ដើម្បីផ្ញើជូនជនរួមជាតិ និងក្នុងគោលបំណងគាំទ្រមនុស្សចាស់នៅកម្ពុជា។

ទិវាមនុស្សចាស់កម្ពុជា និងទិវាមនុស្សចាស់អន្តរជាតិថ្ងៃទី១ ខែតុលា ត្រូវបានរៀបចំស្របតាមគោល

នយោបាយជាតិ ស្តីពីមនុស្សវ័យចាស់នៃព្រះរាជាណាចក្រកម្ពុជា និងសេចក្តីសម្រេចរបស់អង្គការសហប្រជាជាតិ។ ការប្រារព្ធទិវានេះមានគោលបំណងលើកកម្ពស់កិច្ចគាំពារដ៏មានប្រសិទ្ធភាពសំដៅលើកស្ទួយសុខុមាលភាពរបស់មនុស្សវ័យចាស់ឲ្យកាន់តែប្រសើរឡើង ហើយទិវានេះក៏បង្ហាញឲ្យឃើញពីតួនាទីដ៏សំខាន់របស់មនុស្សវ័យចាស់បុព្វការីជនដែលបានបង្កើតធនធានដ៏មានសារប្រយោជន៍ ព្រមទាំងផ្តល់នូវចំណេះដឹងចំណេះធ្វើ និងបទពិសោធយ៉ាងច្រើនឥតគណនាសម្រាប់មនុស្សជំនាន់ក្រោយ។ ក្នុងគោលបំណងយកចិត្តទុក្ខដាក់ខ្ពស់ចំពោះមនុស្សវ័យចាស់កម្ពុជា រាជរដ្ឋាភិបាលបានបង្កើតគណៈកម្មាធិការជាតិកម្ពុជាដើម្បីមនុស្សចាស់ ដើម្បីអនុវត្តតួនាទីនិងភារកិច្ចដែលមានជាអាទិ៍ រៀបចំគោលនយោបាយ ដើម្បីលើកស្ទួយសុខុមាលភាពរបស់មនុស្សវ័យចាស់ និងរៀបចំទិវាមនុស្សចាស់នៃព្រះរាជាណាចក្រកម្ពុជា ដោយកំណត់យកថ្ងៃទី១ ខែតុលា ជារៀងរាល់ឆ្នាំ រួមជាមួយមនុស្សចាស់អន្តរជាតិ[១]។

អង្គប្រជុំបានពិនិត្យពិភាក្សាលើសេចក្តីព្រាងឯកសារទាំងនេះ ហើយបានសម្រេចកែសម្រួល ទម្រង់ខ្លឹមសារ ពាក្យពេចន៍ និងឃ្លាប្រយោគផ្សេងទៀត ដើម្បីធ្វើឲ្យសេចក្តីព្រាងនេះកាន់តែល្អ៕



(១) អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងសារាចរស្តីពីការរៀបចំទិវាមនុស្សចាស់កម្ពុជា និងទិវាមនុស្សចាស់អន្តរជាតិឆ្នាំ២០១៨។

# ១- សិក្ខាសាលាផ្សព្វផ្សាយស្តីពី ការវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត នៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ




កាលពីថ្ងៃពុធ ៨កើត ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី២០ ខែមិថុនា ឆ្នាំ ២០១៨ ក្រុមការងារ RIA នៃក្រសួងកសិកម្ម រុក្ខប្រមាញ់ និងនេសាទ និងក្រុមប្រតិបត្តិលិខិតបទដ្ឋានគតិយុត្ត នៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ បានរៀបចំសិក្ខាសាលាស្តីពីការវាយតម្លៃលើផលប៉ះពាល់ នៃលិខិតបទដ្ឋានគតិយុត្ត(RIA)ដល់ថ្នាក់ដឹកនាំ និងមន្ត្រីនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រមាណ ២០០នាក់ នៅទីស្តីការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រោមអធិបតីភាព ឯកឧត្តម **វេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ក្នុងឱកាសនេះ ឯកឧត្តម **ឃឹម ណុលសន** អនុប្រធាន ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និងជាប្រធានក្រុមប្រតិបត្តិលិខិតបទដ្ឋានគតិយុត្ត បានមានមតិចាប់អារម្មណ៍ក្នុងកម្មវិធីបើកអង្គសិក្ខាសាលា។

ធនាគារអភិវឌ្ឍន៍អាស៊ី ADB រួមជាមួយរាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៃទីស្តីការគណៈរដ្ឋមន្ត្រី បានបង្កើតគម្រោងវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត



ហៅ កាត់ថា RIA។ ការបង្កើតគម្រោង RIA ក្នុងបំណងពង្រឹងការធ្វើកំណែទម្រង់បញ្ញត្តិកម្ម សម្រេចបានឲ្យនូវវប្បធម៌បង្កើតគោលនយោបាយ និងអភិបាលកិច្ច កាន់តែប្រសើរ តាមរយៈការដាក់ឲ្យអនុវត្តប្រព័ន្ធវាយតម្លៃលើលិខិតបទដ្ឋានគតិយុត្ត ពោលគឺជំរុញឲ្យមានការវាយតម្លៃ និងសិក្សាឲ្យបានល្អិតល្អន់បំផុតមុនចេញលិខិតបទដ្ឋានគតិយុត្ត និងបញ្ញត្តិកម្ម ធ្វើយ៉ាងណាកាត់បន្ថយផលប៉ះពាល់ជាអតិបរមានៅក្នុងសង្គម។

ក្នុងឱកាសថ្លែងបើកអង្គសិក្ខាសាលា ឯកឧត្តមរដ្ឋមន្ត្រី **ចេង សាខុន** បានលើកឡើងថា សិក្ខាសាលាផ្សព្វផ្សាយ ស្តីពីការវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត ហៅថា "RIA" នេះ មានសារៈសំខាន់ណាស់ លើកំណែទម្រង់ក្របខ័ណ្ឌច្បាប់នៅប្រទេសកម្ពុជា។ ការវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្តនេះ មានគោលបំណងធ្វើឱ្យរាល់ការកសាងលិខិតបទដ្ឋានគតិយុត្ត ចាប់តាំងពីពេលនេះ និងទៅថ្ងៃអនាគត អនុវត្តតាមនីតិវិធី និងវិធីសាស្ត្រវាយតម្លៃច្បាស់លាស់ សំដៅលើកកម្ពស់ប្រសិទ្ធភាពបញ្ញត្តិកម្ម ដោយបង្កើតឱ្យមានគោលការណ៍អនុវត្តល្អ ក្នុងការតាក់តែងលិខិតបទដ្ឋានគតិយុត្ត របស់ក្រសួង ស្ថាប័ននៃរាជរដ្ឋាភិបាលកម្ពុជា។ នៅក្នុងន័យនេះ វិធីសាស្ត្រ "RIA" ជួយឱ្យយើងមានមូលដ្ឋាន នៃការ





ត្រួតពិនិត្យបានកាន់តែគ្រប់ជ្រុងជ្រោយថែមទៀត មុននឹងដាក់ចេញនូវបញ្ញត្តិកម្មថ្មីណាមួយ។ ជាមួយគ្នានេះដែរ វាអាចកាត់បន្ថយសុពលភាពលិខិតបទដ្ឋានគតិយុត្តត្រួតគ្នា កាត់បន្ថយការិយាធិបតេយ្យ កាត់បន្ថយបានជាអតិបរមានូវផលប៉ះពាល់អវិជ្ជមានទៅលើវិស័យធុរកិច្ច ព្រមទាំងធានាការលើកកម្ពស់ប្រសិទ្ធភាពសេដ្ឋកិច្ច។ ផ្អែកតាមបទពិសោធន៍ប្រទេសអភិវឌ្ឍន៍ជាសមាជិក OECD និងប្រទេស ASEAN មួយចំនួនបានយក "RIA" ជាឧបករណ៍នីតិវិធីក្នុងការរៀបចំលិខិតបទដ្ឋានគតិយុត្តបានល្អប្រសើរ។

បន្ទាប់ពីឯកឧត្តមរដ្ឋមន្ត្រីប្រកាសបើកអង្គសិក្ខាសាលា ឯកឧត្តម **មុិច សុខា** អគ្គលេខាធិការរង និងជាអនុប្រធានអចិន្ត្រៃយ៍នៃក្រុមប្រតិបត្តិលិខិតបទដ្ឋានគតិយុត្ត បានធ្វើបទបង្ហាញពីទិដ្ឋភាពរួមនៃវិធីសាស្ត្រវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត ដល់សិក្ខាកាមទាំងអស់ ឲ្យបានយល់ដឹងអំពីសារៈប្រយោជន៍ពីការប្រើប្រាស់វិធីសាស្ត្រនេះ។

អង្គសិក្ខាសាលាពេញមួយព្រឹកនេះ បានផ្តល់ផ្លែផ្កាជាច្រើនដល់មន្ត្រីនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឲ្យបានយល់ដឹងពីវិធីសាស្ត្រ RIA ហើយនឹងរួមសហការគ្នាក្នុងការអនុវត្តកម្មវិធី RIA ប្រកបដោយជោគជ័យ ជូនក្រសួងនាពេលខាងមុខ៕

# ២- សិក្ខាសាលាផ្សព្វផ្សាយស្តីពី
# ការវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត
## នៅក្រសួងសុខាភិបាល




កាលពីថ្ងៃអង្គារ ១៤កើត ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៨ ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដោយមានការជួយគាំទ្រពីធនាគារអភិវឌ្ឍន៍អាស៊ី ADB បានរៀបចំសិក្ខាសាលាស្តីពីការវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត( RIA ) សម្រាប់មន្ត្រីសុខាភិបាល នៅសណ្ឋាគារសុខាភ្នំពេញ ក្រោមអធិបតីភាព ឯកឧត្តម **ឃឹម ណុលសន** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និងជាប្រធានក្រុមប្រតិបត្តិលិខិតបទដ្ឋានគតិយុត្ត និងឯកឧត្តម **ស៊ា ហួខ** អនុរដ្ឋលេខាធិការ ក្រសួងសុខាភិបាល ។

ធនាគារអភិវឌ្ឍន៍អាស៊ី ADB រួមជាមួយរាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៃទីស្តីការគណៈរដ្ឋមន្ត្រី បានបង្កើតគម្រោងវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត ហៅកាត់ថា RIA។ ការបង្កើតគម្រោង RIA ក្នុងបំណងពង្រឹងការធ្វើកំណែទម្រង់បញ្ញត្តិកម្ម សម្រេចបាននូវវប្បធម៌បង្កើតគោលនយោបាយ និងអភិបាលកិច្ចកាន់តែប្រសើរ តាមរយៈការដាក់ឲ្យអនុវត្តប្រព័ន្ធវាយតម្លៃលើលិខិតបទដ្ឋានគតិយុត្ត ពោលជំរុញឲ្យមានការវាយតម្លៃ និងសិក្សាឲ្យបានល្អិតល្អន់បំផុតមុនចេញលិខិតបទដ្ឋានគតិយុត្ត និងបញ្ញត្តិកម្ម ធ្វើយ៉ាងណាកាត់បន្ថយផលប៉ះពាល់ជាអតិបរមានៅក្នុងសង្គម។

ឯកឧត្តម **ឃឹម ណុលសន** និងឯកឧត្តម **ស៊ា ហួខ** បានថ្លែងថា ការធ្វើបញ្ញត្តិកម្មមានសារសំខាន់

ណាស់ និងចាំបាច់សម្រាប់សង្គមនីមួយៗ ដើម្បីគ្រប់គ្រងសង្គមឲ្យចម្រើន និងប្រសើរឡើង តែវាក៏នាំមកនូវផលប៉ះពាល់ផងដែរ ជៀសមិនផុតឡើយ តែរាជរដ្ឋាភិបាលក៏ត្រូវតែប្រុងប្រយ័ត្នធ្វើកុំឲ្យបញ្ញត្តិកម្មទាំងនោះមានផលអវិជ្ជមានមិនចាំបាច់ដល់អ្នកប្រតិបត្តិតាម។ «RIA ទាមទារឲ្យក្រសួងត្រូវអនុវត្តគោលការណ៍ប្រតិបត្តិធ្វើបញ្ញត្តិកម្មល្អក្នុងការរៀបចំសំណើលិខិតបទដ្ឋានគតិយុត្ត និងវាយតម្លៃឲ្យបានល្អិតល្អន់លើបញ្ញាត្តិកម្មណាមានផលប៉ះពាល់ដល់សង្គម និងសេដ្ឋកិច្ច»។

ក្នុងឱកាសនោះ ឯកឧត្តម **ម៉ិច សុខា** អគ្គលេខាធិការរង និងជាអនុប្រធានក្រុមប្រតិបត្តិលិខិតបទដ្ឋានគតិយុត្តបានធ្វើបង្ហាញពីទិដ្ឋភាពរួមនៃវិធីសាស្រ្តវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្តដល់សិក្ខាកាមទាំងអស់ ឲ្យបានយល់ដឹងអំពីសារៈប្រយោជន៍ពីការប្រើប្រាស់វិធីសាស្រ្តនេះ។

អង្គសិក្ខាសាលាពេញមួយព្រឹកនេះបានផ្តល់ផ្លែផ្កាជាច្រើនដល់មន្រ្តីសុខាភិបាល ឲ្យបានយល់ដឹងពីវិធីសាស្រ្ត RIA ហើយនឹងរួមសហការគ្នាក្នុងការអនុវត្តកម្មវិធី RIA ប្រកបដោយជោគជ័យជូនក្រសួង នាពេលខាងមុខ៕



# III- កិច្ចប្រជុំស្តីពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា ប្រចាំខែឧសភា ឆ្នាំ២០១៨



របាយការណ៍ស្តីពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ **ប្រចាំខែឧសភា ឆ្នាំ២០១៨** នេះ ជាលទ្ធផលនៃកិច្ចប្រជុំទូលាយក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) នៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ក្រោមអធិបតីភាព ឯកឧត្តម **យឹម ណុលឡា** ទេសរដ្ឋមន្ត្រីទទួលបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដោយមានការអញ្ជើញចូលរួមពី អនុប្រធាន សមាជិក សមាជិកា អគ្គលេខាធិការ អគ្គលេខាធិការរង នៃ ក.ស.វ. និងតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធ។

## ១) ស្ថានភាពសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងអត្រាប្តូរប្រាក់

➡ នាខែឧសភា ឆ្នាំ២០១៨សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់កើនឡើង០,៣% ធៀបនឹងខែមុន និងកើនឡើង២,៩% ធៀបនឹងខែដូចគ្នាឆ្នាំមុន (រយៈពេល១២ខែ)។

តារាង១.១. បម្រែបម្រួលថ្លៃធៀបនឹងខែដូចគ្នាឆ្នាំមុនសម្រាប់ក្រុមទំនិញនិងមុខទំនិញមួយចំនួន

| *ក្រុមទំនិញ:* | | *មុខទំនិញ:* | |
|---|---|---|---|
| ភោជនីយដ្ឋាន: | +៤,៣% | ប្រេងសាំង: | +៩,១% |
| ទំនិញ និងសេវាកម្មផ្សេងៗ | +៣,៩% | ឧស្ម័ន | +៨,៥% |
| ការដឹកជញ្ជូន: | +៣,៩% | ប្រេងម៉ាស៊ូត: | +៧,៣% |
| ម្ហូបអាហារ: | +៣,៣% | ត្រីស្រស់: | +៥,៦% |
| ផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ទនៈផ្សេងទៀត | +១,៧% | សាច់គោ: | +៤,២% |
| សុខាភិបាល: | +១,៧% | សាច់មាន់: | +៣,១% |
| សំលៀកបំពាក់ និងស្បែកជើង: | +១,៤% | សាច់ជ្រូក: | +១,៣% |
| គ្រឿងសង្ហារឹមនិងសម្ភារៈប្រើប្រាស់: | +០,៥% | | |

តារាង១.២. បម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ ២០១៦–២០១៨

| ឆ្នាំ | ធៀបនឹងខែ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា P | កក្កដា P | សីហា P | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | ប្រចាំឆ្នាំ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ២០១៨ | ដូចគ្នាឆ្នាំមុន | ២,០% | ២,៣% | ២,៣% | ២,៤% | ២,៩% | ៣,០% | ២,៩% | ២,៦% | | | | | |
| | មុន | ០,១% | ០,៤% | ០,០៤% | ០,៥% | ០,៣% | ០,២% | ០,២% | ០,២% | | | | | |
| ២០១៧ | ដូចគ្នាឆ្នាំមុន | ៤,៤% | ៤,០% | ៤,២% | ៣,២% | ២,៥% | ២,៣% | ២,៣% | ២,៦% | ២,៧% | ២,១% | ២,៣% | ២,២% | ២,៩% |
| | មុន | ០,៣% | ០,១% | ០,០% | ០,៤% | -០,២% | ០,១% | ០,៣% | ០,៤% | ០,៣% | -០,២% | ០,២% | ០,៤% | |
| ២០១៦ | ដូចគ្នាឆ្នាំមុន | ៣% | ២,៣% | ២,០% | ២,៨% | ៣,១% | ៣,៣% | ៣,០% | ២,៩% | ៣,០% | ៣,៤% | ៣,៦% | ៣,៩% | ៣% |
| | មុន | -០,២% | ០,៤% | -០,២% | ១,៤% | ០,៥% | ០,២% | ០,៣% | ០,២% | ០,៣% | ០,៤% | ០ | ០,៤% | |

P: តួលេខខែមិថុនា កក្កដា និងសីហាឆ្នាំ២០១៨ ជាតួលេខព្យាករ (តាមវិធីសាស្ត្រ DECOMPOSITION)

* ការវិភាគជាសំណេរដកស្រង់ចេញពីទិន្នន័យសំខាន់ៗប៉ុណ្ណោះ មិនគ្របដណ្តប់តួលេខទាំងអស់ទេ (មើលតារាងភ្ជាប់មកជាមួយ)។
* ដើម្បីមានសង្គតិភាពក្នុងការប្រើប្រាស់លេខខ្មែរ និងអន្តរជាតិ សញ្ញាក្បៀសនៅក្នុងអត្ថបទ តាងឲ្យទសភាគ។ ប៉ុន្តែក្នុងតារាងលេខ (Excel) សញ្ញាក្បៀសតាងឲ្យខ្ទង់ពាន់ ឯសញ្ញាចុចជាទសភាគវិញ។

ក្រាហ្វ ១.១. ចលនានិងបម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់តារាង







១.៣. អត្រាប្តូរប្រាក់

| *ប្រភេទ* | *ឧសភា* ២០១៨ | *មេសា* ២០១៨ | *ឧសភា* ២០១៧ | *ប្រភេទ* | *ឧសភា* ២០១៨ | *មេសា* ២០១៨ | *ឧសភា* ២០១៧ |
|---|---|---|---|---|---|---|---|
| **៛/ដុល្លារ** | ៤០៧៥៛/១$ | ៤០៣២៛/១$ | ៤០៦៩៛/១$ | **បាត/ដុល្លារ** | ៣២,០៣បាត/១$ | ៣១,៥០បាត/១$ | ៣៤,១២បាត/១$ |
| **៛/បាត** | ១២៧៛/១បាត | ១២៨៛/១បាត | ១១៩៛/១បាត | **ដុង/ដុល្លារ** | ២២៨១៥ដុង/១$ | ២២៧២០ដុង/១$ | ២២៧១០ដុង/១$ |
| **៛/ដុង** | ០,១៧៩៛/១ដុង | ០,១៧៧៛/១ដុង | ០,១៧៩៛/១ដុង | | | | |

## ២) ស្ថានភាពថវិកាជាតិ

➡យោងតាមស្ថិតិរបស់ធនាគារជាតិ អគ្គនាយកដ្ឋានគយនិងរដ្ឋាករ និងអគ្គនាយកដ្ឋានពន្ធដារក្នុងខែឧសភា ឆ្នាំ ២០១៨ ថវិកាជាតិមានស្ថានភាពដូចខាងក្រោម:

**២.១. ចំណូលថវិកាជាតិ** : អនុវត្តបាន១៦៧១,៥ប៊ីលានរៀល គិតជាដុល្លារអាមេរិកស្មើ ៤១៧,៨ លានដុល្លារ ( *មធ្យមប្រចាំខែ ១០២,៣% នៃផែនការ*) ក្នុងនោះចំណូលចរន្តចំនួន១៥៧០ប៊ីលានរៀល គិតជាដុល្លារអាមេរិកស្មើ ៣៩២,៥ លានដុល្លារ ( *មធ្យមប្រចាំខែ ១០២% នៃផែនការ*) និងចំណូលមូលធនចំនួន ១០១,៥ប៊ីលានរៀល (តាមតួលេខ ធនាគារជាតិ)។

ក្រាហ្វ ២.១. ចំណូលថវិកាជាតិ ឆ្នាំ ២០១៦-២០១៨ (ប៊ីលានរៀល)




➢បើធៀបនឹងខែមុន ចំណូលថវិកាជាតិថយចុះ៩,៨% ប៉ុន្តែកើនឡើង១៣,៨%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢នៅក្នុងចំណូលចរន្ត:

✓ចំណូលសារពើពន្ធមានចំនួន ១៤៣២,២ប៊ីលានរៀលថយចុះ១០,៩% ធៀបនឹងខែមុនប៉ុន្តែ កើនឡើង ២១,១% ធៀបនឹងខែដូចគ្នាឆ្នាំមុន(តាមតួលេខ ធនាគារជាតិ)។

✓ចំណូលមិនមែនសារពើពន្ធ មានចំនួន១៣៧,៩ប៊ីលានរៀលថយចុះ២៨,៩% ធៀបនឹងខែមុន និងថយចុះ ២៣,៦% ធៀបនឹងខែដូចគ្នាឆ្នាំមុន(តាមតួលេខ ធនាគារជាតិ)។

**តារាង២.១. មុខចំណូលមួយចំនួនក្នុងចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ**

| **ចំណូលសារពើពន្ធ** (ក្នុងវង់ក្រចក:បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន) | | **ចំណូលមិនមែនសារពើពន្ធ** (តាមតួលេខ រតនាគារជាតិ) (ក្នុងវង់ក្រចក:បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន) | |
|---|---|---|---|
| ➢ ពន្ធ និងអាករគយ: +១៥,៥% (អគ្គនាយកដ្ឋានគយ និងរដ្ឋាករ) | (+៣២,៤%) | ➢កាស៊ីណូ : -៦,១% | (-២៣,២%) |
| | | ➢អាជ្ញាបណ្ណក្នុងស្រុក : -៧៤,៧% | (+៥៣,៣%) |
| ➢ ចំណូលពន្ធដារ: -៣២,៧% (អគ្គនាយកដ្ឋានពន្ធដារ) | (+១៥,៣%) | ➢ នេសាទ:+១៨៦,៩% | (-៤៤,0%) |
| | | ➢សម្បទានរ៉ែ: +៦៦,៩% | (+២៩៤,៤%) |
| | | ➢ អាកាសចរណ៍ស៊ីវិល: +៦១២,0% | (-២៨,២%) |

**២.២. ចំណាយថវិកាជាតិ** :អនុវត្តបាន ១២៩៩,៧ប៊ីលានរៀល គិតជាដុល្លារអាមេរិកស្មើ ៣២៤,៩២ លានដុល្លារ (*មធ្យមប្រចាំខែ ៦៧% នៃផែនការ*) ក្នុងនោះ ចំណាយចរន្តចំនួន ១១៤៣,៦ប៊ីលានរៀល (*មធ្យមប្រចាំខែ ៧៧% នៃផែនការ*) និងចំណាយមូលធនមានចំនួន១៥៦,១ប៊ីលានរៀល(តាមតួលេខ រតនាគារជាតិ)។

➢ចំណាយថវិកាជាតិកើនឡើង១៧% ធៀបនឹងខែមុន និងកើនឡើង១១,៤%ធៀបនឹងខែដូចគ្នាឆ្នាំមុន។ ក្នុងនោះចំណាយចរន្តកើនឡើង២១,២%ធៀបនឹងខែមុន និងកើនឡើង៧,៣%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

**២.៣. សមតុល្យថវិកាជាតិ** : ថវិកាជាតិនាខែនេះមានអតិរេកចំនួន ៣៧១,៩ប៊ីលានរៀល គិតជាដុល្លារអាមេរិក ស្មើ ៩២,៩៦លានដុល្លារ (តួលេខរតនាគារជាតិ)។

ក្រាហ្វ២.២. ចំណាយថវិកាជាតិ ឆ្នាំ ២០១៦-២០១៨ (ប៊ីលានរៀល)




## ៣) ស្ថានភាពរូបិយវត្ថុនិងអត្រាការប្រាក់

➡ស្ថានភាពរូបិយវត្ថុ ក្នុងខែឧសភា ឆ្នាំ២០១៨មានលក្ខណៈដូចខាងក្រោម:

➢រូបិយវត្ថុ$M_2$ មានចំនួន៧៨១១ប៊ីលានរៀលកើនឡើង២,៣%ធៀបនឹងខែមុន និងកើនឡើង២៤,១% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ **ការកើនឡើង$M_2$** ក្នុងខែនេះ ជារួមបណ្តាលមកពីការកើនឡើងនៃប្រាក់បញ្ញើចរន្ត២០,៩% ប្រាក់បញ្ញើមានកាលកំណត់ និងសន្សំ ១១% និងប្រាក់បញ្ញើជារូបិយបណ្ណ២,៣%។

ក្រាហ្វ៣.១. សមាសធាតុរូបិយវត្ថុខែឧសភាឆ្នាំ២០១៨




➢ក្នុងខែនេះ ប្រាក់រៀលសរុបនៅក្នុងនិងក្រៅធនាគារមានចំនួន១៥,៣% និងប្រាក់បញ្ញើជារូបិយបណ្ណមានចំនួន ៨៤,៧% នៃរូបិយវត្ថុ$M_2$។

តារាង៣.១. សមាមាត្រចំនួនប្រាក់រៀល នៅក្នុងរូបិយវត្ថុ M2 ឆ្នាំ២០១៨

| ប្រាក់រៀលសរុបនៅក្នុងនិងក្រៅធនាគារ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ១៦,៨% | ១៦,៧% | ១៥,៥% | ១៥,៣% | ១៥,៣% | | | | | | | |
| ប្រាក់រៀលក្រៅធនាគារ | ១១,៦% | ១១,៥% | ១១,៣% | ១១,៤% | ១១,៩% | | | | | | | |

ក្រាហ្វ៣.២.បម្រែបម្រួលសមាសធាតុរូបិយវត្ថុខែឧសភា ២០១៨: ក្នុងរង្វង់ក្រចកជាបម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន




➢**ទុនបម្រុងជារូបិយបណ្ណបរទេសសុទ្ធ** មានចំនួន៨៩៩៧លានដុល្លារ កើនឡើង១,៤%ធៀបនឹងខែមុន និងកើនឡើង១៨,៩% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢ ***ប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជនៅធនាគារជាតិ*** ក្នុងខែនេះមានចំនួន ២៨៩៧១ ប៊ីលានរៀលកើនឡើង៥,៤%ធៀបនឹងខែមុន និងកើនឡើង២៦,៣%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

តារាង៣.២.ការផ្តល់ឥណទាននិងអត្រាការប្រាក់ប្រចាំឆ្នាំ

| ផ្តល់ដោយ | ឧសភា២០១៨ | មេសា២០១៨ | ឧសភា២០១៧ |
|---|---|---|---|
| ឥណទានផ្តល់ដោយធនាគារពាណិជ្ជ( ប៊ីលានរៀល ) | ៧២៧៧០ | ៧១៤៦៩ | ៦០៧០៣ |
| ក្នុងនោះ ជារៀល | | | ១០៥៤ |
| ឥណទានផ្តល់ដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ( ប៊ីលានរៀល ) | | ១៨៦៨២ | ១៤២៧៥ |
| អត្រាការប្រាក់បញ្ញើជារៀលនៅធនាគារពាណិជ្ជ | ៥,៩៧% | ៥,៩៧% | ៥,៩៩% |
| អត្រាការប្រាក់កម្ចីជារៀលនៅធនាគារពាណិជ្ជ | ១១,៦០% | ១១,៥៩% | ១៤,៤២% |
| អត្រាការប្រាក់បញ្ញើជាដុល្លារនៅធនាគារពាណិជ្ជ | ៤,៤២% | ៤,៤១% | ៤,៤០% |
| អត្រាការប្រាក់កម្ចីជាដុល្លារនៅធនាគារពាណិជ្ជ | ១១,៣៦% | ១១,២៧% | ១១,៧៣% |
| អត្រាការប្រាក់កម្ចីជារៀលនៅហត្ថកសិករ | ១៨% | ១៨% | ១៥% |
| អត្រាការប្រាក់កម្ចីជារៀលនៅអម្រឹត | ១៨% | ១៨% | ២៧% |
| អត្រាការប្រាក់កម្ចីជារៀលនៅប្រាសាក់ | ១៤,០% | ១៧,៩% | ២២,៨% |

## ៤)ស្ថានភាព កសិកម្ម ឧស្សាហកម្ម សេវាកម្ម និងថាមពល

➡ក្នុងខែឧសភា ឆ្នាំ២០១៨ ស្ថានភាពផលិតកម្មមានលក្ខណៈដូចខាងក្រោម:

➢**កសិកម្ម**:

✓នេសាទសម្រេចបាន៥៤,១ពាន់តោនកើនឡើង៦% ធៀបនឹងខែមុននិង កើនឡើង៨,៧%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢**រ៉ែ និងថាមពល**:

✓អគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជាមានចំនួន៧៨១,២៥GWHមានការកើនឡើង០,៨%ធៀបនឹងខែមុន និងកើនឡើង២១%ធៀបនឹងខែដូចគ្នាឆ្នាំមុន ក្នុងនោះផ្គត់ផ្គង់ដោយវារីអគ្គិសនីមានចំនួន៣៩៦,២៥GWH មានការ កើនឡើង៩១,១% ធៀបនឹងខែមុន និងកើនឡើង៣៤%ធៀបនឹងខែដូចគ្នាឆ្នាំមុន អគ្គីសនីផ្គត់ផ្គង់ដោយធ្យូងថ្មមានចំនួន៣០៦,៦៣GWHមានការថយចុះ១៩,៧% ធៀបនឹងខែមុន ប៉ុន្តែមានការ កើនឡើង១១% ធៀប

នឹងខែដូចគ្នាឆ្នាំមុន អគ្គិសនីដែលនាំចូលពីប្រទេសជិតខាងដោយ EDC មានចំនួន៦៧,១៥GWHមានការ ថយចុះ៥៥% ធៀបនឹងខែមុន ប៉ុន្តែមានការកើនឡើង១%ធៀបនឹងខែដូចគ្នាឆ្នាំមុន និងអគ្គិសនីផ្គត់ផ្គង់ដោយប្រភពផ្សេងទៀតមានចំនួន១១,២២GWHមានការថយចុះ៦៩,៥% ធៀបនឹងខែមុន ប៉ុន្តែមានការកើនឡើង២% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢**ឧស្សាហកម្ម**:

✓ផលិតកម្មវាយនភណ្ឌនិងស្បែកជើងមានចំនួន ៦៥៣លានដុល្លា ថយចុះ២%ធៀបនឹងខែមុនប៉ុន្តែ កើនឡើង ១២,៨%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

តារាង៤.១. ការចុះបញ្ជីរោងចក្រ និងឧស្សាហកម្មធុនតូច និងសិប្បកម្ម នៅក្រសួងឧស្សាហកម្ម

| *ប្រភេទ* | *ចំនួន—ឧសភា២០១៨* | *ចំនួន—មេសា២០១៨* | *ចំនួន—ឧសភា២០១៧* |
|---|---|---|---|
| ▪រោងចក្រថ្មីដែលបានចុះបញ្ជី | ១៦ | ១៣ | ៥ |
| ▪ ចំនួនរោងចក្រសរុបដែលមានក្នុងបញ្ជី | ១៥៨៥ | ១៥៦៩ | ១៦១២ |
| ▪ ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បើកថ្មី) | ១១ | ៩ | ១៤ |
| ▪ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បន្ត) | ២២ | ១៦ | ២១ |

➢**សំណង់** (ការអនុញ្ញាត):

✓សំណង់អនុញ្ញាតឲ្យសាងសង់មានចំនួន៣៣០,៥ពាន់ម៉$^{២}$ មានការថយចុះ៨៩%ធៀបនឹងខែមុន និងថយចុះ៥០%ធៀបនឹងខែដូចគ្នាឆ្នាំមុន។ បើគិតជាសាច់ប្រាក់ស្មើនឹង១៣៨,៩លានដុល្លារមានការថយចុះ៨៨% ធៀបនឹងខែមុន និងថយចុះ៥៩%បើធៀបនឹងខែដូចគ្នាឆ្នាំមុន។ ក្នុងនោះប្រភេទសំណង់ចម្បងៗមាន:

តារាង៤.២. សំណង់អនុញ្ញាតតាមប្រភេទផ្សេងៗ

| *ប្រភេទ* | *ពាន់ម៉$^{២}$— ឧសភា២០១៨* | *ពាន់ម៉$^{២}$—មេសា២០១៨* | *ពាន់ម៉$^{២}$—ឧសភា២០១៧* |
|---|---|---|---|
| ▪ លំនៅឋាន | ១៩៦,៣ | ៩៤៨,០ | ៤៥៥,១ |
| ▪ ឧស្សាហកម្ម | ៣៩,០ | ៥,៩ | ២២,៥ |
| ▪ពាណិជ្ជកម្ម | ២៩,៨ | ៤៧,៦ | ១៤៤,៥ |
| ▪ ទេសចរណ៍ | ៦២,២ | ១៨៨៥,៣ | ៤១,៦ |
| ▪ផ្សេងៗ | ០,០ | ០,០ | ០,៤ |
| អនុញ្ញាតសរុប | ៣៣០,៥ | ៣០០៥,៤ | ៦៦៥,៩ |

✓ ដូច្នេះសំណង់អនុញ្ញាតដែលពេញនិយមនាខែនេះគឺលំនៅឋាន៥៩,៣%និង ទេសចរណ៍១៨,៨% នៃផ្ទៃក្រឡាសរុប។

➢**ការងារ**

តារាង៤.៣. ការស្វែងរកការងារនិងទទួលបានការងារ

| *ប្រភេទ* | *នាក់— ឧសភា ២០១៨* | *នាក់—មេសា ២០១៨* | *នាក់—ឧសភា ២០១៧* |
|---|---|---|---|
| អ្នកចុះឈ្មោះស្វែងរកការងារ (ទីភ្នាក់ងារជាតិមុខរបរនិងការងារ) | ៩០១ | ១៥២៨ | ៧៥១ |
| អ្នកទទួលបានការងារតាមរយៈក្រសួងការងារ និងក្រុមហ៊ុន | ១៧៣៩០ | ១៧៨៧៦ | ១៣៣៧៥ |
| អ្នកទទួលបានការងារក្នុងប្រទេស | ១២១២៧ | ១៣២៨៦ | ៩៦៧៦ |
| អ្នកទទួលបានការងារក្រៅប្រទេស | ៥២៦៣ | ៤៥៩០ | ៣៦៩៩ |

### ➢វិនិយោគ

តារាង៤.៤.គម្រោងវិនិយោគអនុញ្ញាតដោយគ.វ.ក./ក.អ.ក. (ថ្មីនិងពង្រីក)

| ប្រភេទ | ឧសភា២០១៨ | មេសា២០១៨ | ឧសភា២០១៧ |
|---|---|---|---|
| អនុញ្ញាតសរុប (លានដុល្លារ) | ១៣,២ | ១៧៨,៣ | ១០០៧,៧ |
| វិស័យកសិកម្មនិងកសិឧស្សាហកម្ម | ០,០ | ០,០ | ០,០ |
| វិស័យឧស្សាហកម្ម (ក្នុងវង់ក្រចកជាតួលេខនៃតំបន់សេដ្ឋកិច្ចពិសេស) | ១៣,២<br>(៣,៥) | ៧៩,៣<br>(១២,៣) | ៣១,៧<br>(៣,៥) |
| វិស័យទេសចរណ៍ | ០,០ | ០,០ | ០,០ |
| វិស័យហេដ្ឋារចនាសម្ព័ន្ធនិងផ្សេងៗ | ០,០ | ៩៩,០ | ៩៧៦,០ |
| ចំនួនគម្រោង ថ្មីនិងពង្រីក (ចំនួន) | ៦,០ | ១៧,០ | ៨,០ |
| បង្កើតការងារ (ពាន់នាក់) | ៤,៨ | ២២,៩ | ៦,៩ |

### ➢សេវាកម្ម

តារាង៤.៥.ការចុះបញ្ជីនិងលុបចេញពីបញ្ជី នៅក្រសួងពាណិជ្ជកម្ម

| ប្រភេទ | ចំនួន—ឧសភា ២០១៨ | ចំនួន—មេសា ២០១៨ | ចំនួន—ឧសភា ២០១៧ |
|---|---|---|---|
| ក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្ម | ៨៣៤ | ៩៤១ | ២៨៣ |
| ក្រុមហ៊ុនត្រូវបានលុបចេញពីបញ្ជីពាណិជ្ជកម្ម | ៤ | ១៤ | ១ |
| ក្រុមហ៊ុនដែលបានចុះបញ្ជីបង់ពន្ធដារតាមរបបពិត | ៦៤១ | ៣៤៣ | ៤៩០ |

➢**ទំនិញឆ្លងកាត់កំពង់ផែ**(សរុប៥កំពង់ផែ) មានចំនួន១០៨៩,៤ពាន់តោនកើនឡើង៦% ធៀបនឹងខែមុន និង កើនឡើង៣០%ធៀបនឹងខែដូចគ្នាឆ្នាំមុនក្នុងនោះៈ

តារាង៤.៦.ទំនិញឆ្លងកាត់កំពង់ផែផ្សេងៗ (ក្នុងវង់ក្រចកៈ បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន)

| | | | |
|---|---|---|---|
| ▪ កំពង់ផែភ្នំពេញៈ+១៧,៨% | (+២០%) | ▪ កំពង់ផែស្រែអំបិល និងកោះកុងៈ-១% | (-២៩%) |
| ▪ កំពង់ផែកំពង់សោមៈ+១៤% | (+២៦,៨%) | ▪ កំពង់ផែឧកញ៉ាម៉ុងៈ -៥៨% | (កើនគំហុគ) |

### ➢ប្រៃសណីយ៍និងទូរគមនាគមន៍

| ប្រភេទ | ចំនួន | %Δ ធៀបនឹងខែមុន | %Δធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|
| បញ្ញើក្នុងប្រទេស(ពាន់កញ្ចប់) | ១៨,៣ | ៧% | -១% |
| ក្នុងនោះទទួល | ២,៣ | ៦% | -៩% |
| បញ្ញើក្រៅប្រទេស(ពាន់កញ្ចប់) | ៨៥,១ | -៧% | -១១,៧% |
| ក្នុងនោះទទួល | ៤៨,៧ | -២% | -២០% |
| សន្ទនាទូរសព្ទក្នុងប្រទេស(ពាន់នាទី) | ១៨៦៥,៧ | ៩% | -២៣% |
| ក្នុងនោះហៅចូល | ៥៤៧ | ៣% | -២២% |
| សន្ទនាទូរសព្ទក្រៅប្រទេស(ពាន់នាទី) | ៧៧១៩,២ | ១៥% | -២៦% |
| ក្នុងនោះហៅចូល | ៧៦៤៨,២ | ១៥% | -២៦% |

➢ **ការធ្វើដំណើរតាមផ្លូវអាកាសនិងទេសចរណ៍**

តារាង៤.៧.អ្នកដំណើរតាមផ្លូវអាកាសនិងទេសចរណ៍

| *ប្រភេទ* | *ចំនួន( ពាន់នាក់ )* | *%∆ ធៀបនឹងខែមុន* | *%∆ធៀបនឹងខែដូចគ្នាឆ្នាំមុន* |
|---|---|---|---|
| ភ្ញៀវអន្តរជាតិចូលទស្សនាសារមន្ទីរជាតិ | ១១,៤ | -២៩% | -៩% |
| អ្នកដំណើរតាមផ្លូវអាកាស (ក្នុងស្រុក) | ៣៨,៣ | -១៧% | ៣% |
| អ្នកដំណើរតាមផ្លូវអាកាស (អន្តរជាតិ) | ៦៥៥ | -៨% | ២៥% |
| ចំនួនទេសចរជាតិចេញក្រៅប្រទេស | ១៥៨,៥ | -២២,៥% | ២% |
| ចំនួនទេសចរអន្តរជាតិមកព្រះរាជាណាចក្រកម្ពុជា | ៤១៨,៣ | -១០% | ១៣% |
| ✓ តាមផ្លូវអាកាស | ២៧១,៨ | -៩% | ២៥% |
| ✓ តាមផ្លូវគោក និងទឹក | ១៤៦,៥ | -១២% | -៣% |

## ៥) ស្ថានភាពពាណិជ្ជកម្ម

➡ពីប្រភពអគ្គនាយកដ្ឋានគយនិងរដ្ឋាករ ការនាំចូលនាខែឧសភា ឆ្នាំ២០១៨ មានចំនួន ៦១០៥,៥ប៊ីលានរៀល (ស្មើនឹង១៥២៦,៤លានដុល្លារ ស.រ.អា.)កើនឡើង២៨,៣%ធៀបនឹងខែមុននិងកើនឡើង២៦%ធៀបនឹងខែដូចគ្នាឆ្នាំមុនក្នុងនោះ

តារាង៥.១.បម្រែបម្រួលនៃការនាំចូលមុខទំនិញមួយចំនួន

| ទំនិញ | %∆ធៀបនឹងខែមុន | %∆ធៀបនឹងខែដូចគ្នាឆ្នាំមុន | ទំនិញ | %∆ធៀបនឹងខែមុន | %∆ធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|---|---|
| ប្រេងសាំង | -៨,២% | +៣,៤% | រថយន្តសរុប (ប៊ី.ល.រ) | +១៥,២% | +៣០,២% |
| ប្រេងម៉ាស៊ូត | +០,៤% | -២,០% | រថយន្តសរុប (គ្រឿង) | +១១,៦% | +៩,០% |
| ឧស្ម័ន | +៣៩,៨% | +២៦,៣% | ត្រាក់ទ័រនិងគោយន្ត(គ្រឿង) | +១៣,២% | +៨,៤% |
| អគ្គិសនីនាំចូលដោយ | -៥៥% | +១% | ម៉ូតូ (គ្រឿង) | +១៦,៦% | +៤% |
| ដែកសំណង់ | +១០,៦% | +៥១,៤% | អង្ករ | +២៤០,៦% | កើនគំហុក |
| ស៊ីម៉ង់ត៍ | +៩,៨% | +៣,៦% | ផ្លែឈើនិងបន្លែ | -០,៣% | -៣០,៤% |
| គ្រឿងអេឡិចត្រូនិក | -០,៦% | +២២៨,៩% | ជីនិងថ្នាំកសិកម្ម | +៧៣,៤% | +៩,៤% |
| | | | នាំចូលក្នុងក្របខណ្ឌច្បាប់វិនិ | +៣,៨% | -០,៦% |

➡ **ការនាំចេញ** ខែឧសភាឆ្នាំ២០១៨ មានចំនួន៤០០៥,៨ប៊ីលានរៀល ស្មើនឹង១០០១,៤លានដុល្លារ ស.រ.អា. (៦៦% នៃការនាំចូល)កើនឡើង៣៤,៨%ធៀបនឹងខែមុន និងកើនឡើង២១%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

តារាង៥.២.បម្រែបម្រួលនៃការនាំចេញមុខទំនិញមួយចំនួន

| *ទំនិញ* | *%∆ធៀបនឹងខែមុន* | *%∆ធៀបនឹងខែដូចគ្នាឆ្នាំមុន* | *ទំនិញ* | *%∆ធៀបនឹងខែមុន* | *%∆ធៀបនឹងខែដូចគ្នាឆ្នាំមុន* |
|---|---|---|---|---|---|
| ផលិតផលឈើកែឆ្នៃ | -១៧,៦% | -៧៤,៧% | ផលិតផលនេសាទ | -៣,៩% | -៣,០% |
| វាយនភណ្ឌនិងស្បែកជើង | +៤១,១% | +៣២,៦% | កៅស៊ូ | +៨៦,៥% | -៦,៤% |
| អង្ករ | -១៧,២% | -៨,៩% | | | |

## ៦) បម្រែបម្រួលគួរឲ្យចាប់អារម្មណ៍

ក្នុងខែឧសភា ឆ្នាំ២០១៨នេះ សូចនាករសេដ្ឋកិច្ច សង្គមកិច្ច នៃព្រះរាជាណាចក្រកម្ពុជាបង្ហាញបម្រែបម្រួលគួរឲ្យចាប់អារម្មណ៍ដូចក្នុងតារាងខាងក្រោម។

តារាង៦.១. បម្រែមប្រួលគួរឲ្យចាប់អារម្មណ៍ នៃសូចនាករមួយចំនួន

| ល.រ | សូចនាករ | ធៀបនឹងខែមុន | ធៀបនឹងខែដូចគ្នាឆ្នាំមុន | កំណត់សម្គាល់ |
|---|---|---|---|---|
| ១ | ថ្លៃប្រេងសាំង | ១,៧% | ៩,១% | |
| ២ | ថ្លៃប្រេងម៉ាស៊ូត | ១,១% | ៧,១% | |
| ៣ | ឧស្ម័ន | ១,៦% | ៨,៥% | |
| ៤ | ការអនុញ្ញាតអោយសាងសង់ | -៨៩% | -៥០% | |

## ៧) សេចក្តីសន្និដ្ឋាន

ប្រទេសកម្ពុជាមានផលិតផលដំណាំកសិកម្មជាច្រើនដែលមានសក្តានុពលអាចនាំចេញបាន ដូចជា អង្ករ កៅស៊ូ ម្រេច ដំឡូងមី ពោត សណ្តែក ។ល។ អង្គប្រជុំបានលើកឡើង ពិភាក្សាអំពីការនាំចេញផលិតផលកសិកម្មក្រៅពីដំណាំស្រូវ នៅតែមានឧបសគ្គច្រើនទោះបីជាមានប្រទេសមួយចំនួនដូចជា ប្រទេសចិនជាដើមបានអនុគ្រោះពន្ធនាំចូលឲ្យផលិតផលកសិកម្មកម្ពុជាក៏ដោយ។ ឧបសគ្គចំបងៗដែលរាំងស្ទះការនាំចេញនេះរួមមាន៖

១) ផលិតផលមិនត្រូវតាមស្តង់ដារ ដែលតម្រូវដោយអ្នកទិញបណ្តាលមកពីកសិករយើងភាគច្រើនមិនមានបច្ចេកទេសដាំដុះរាប់ចាប់ពីការយល់ពីស្ថានភាពដី ការជ្រើសរើសពូជ ការដាក់ជី ការថែទាំ ការប្រមូលផល ការវេចខ្ចប់ និងការស្តុកទុកជាដើម។

២) ផលិតផលដែលផលិតបានមានថ្លៃដើមខ្ពស់ពេក មិនអាចប្រកួតប្រជែងជាមួយប្រទេសជិតខាងបានដែលបណ្តាលមកពីកត្តាជាច្រើនដូចជា ការប្រើប្រាស់ជីហួសពីតម្រូវការ ឬខុសពីស្ថានភាពដី ថ្លៃដឹកជញ្ជូន ថ្លៃវេចខ្ចប់ ថ្លៃស្តុកទុក ថ្លៃដើមទុនខ្ពស់ពេកជាដើម។

៣) ការផលិតមានខ្នាតតូចពេក ហើយនៅរាយប៉ាយមិនអាចឆ្លើយតបតាមតម្រូវការបញ្ជាទិញ និងការផ្គត់ផ្គង់ផលិតផលគ្មានស្ថេរភាព។

៤) ការដាំដុះដោយផ្អើលតាមគ្នា មិនបានទទួលព័ត៌មាន និងមិនបានសិក្សាពីតម្រូវការទីផ្សារឲ្យបានម៉ត់ចត់នាំឲ្យការផលិតបានហើយ រកទីផ្សារលក់មិនបាន នាំដល់ការខាតបង់ទ្រព្យសម្បត្តិ និងជំពាក់បំណុលវិន្តក។

៥) បញ្ហាភូតគាមអនាម័យដែលតម្រូវដោយប្រទេសនាំចូលផលិតផលកសិកម្ម គឺជាឧបសគ្គដែលមិនទាន់អាចដោះស្រាយបាន។

ដើម្បីដោះស្រាយបញ្ហាប្រឈមខាងលើ វិធានការមួយចំនួនគួរតែត្រូវបានជំរុញ ដូចតទៅ៖

១) គួរតែបង្កើតស្តង់ដាផលិតផលកសិកម្ម ឲ្យបានច្បាស់លាស់ នឹងមានការផ្សព្វផ្សាយនឹងណែនាំដល់កសិករអនុវត្តតាម។

២) គួរតែមានការណែនាំបច្ចេកទេសក្នុងការដាំដុះរាល់មុខដំណាំ ចាប់ពីការជ្រើសរើសពូជ ការដាក់ជី ការថែទាំរហូតដល់ការប្រមូលផល។ល។ ហើយផ្សព្វផ្សាយឲ្យបានទូលំទូលាយតាមគ្រប់មធ្យោបាយ ដើម្បីឲ្យប្រជាជនបានយល់ដឹងជាទូទៅនូវបច្ចេកទេសដាំដុះ។

៣) គួរតែមានកិច្ចសហការ រវាងស្ថាប័នពាក់ព័ន្ធ ដើម្បីដោះស្រាយរាល់បញ្ហាដែលទាក់ទងដល់ការនាំចេញផលិតផលកសិកម្ម។

៤) គួរតែដោះស្រាយបញ្ហាភូតគាមអនាម័យ ឲ្យបានឆាប់រហ័សដើម្បីជំរុញការនាំចេញផលិតផលកសិកម្ម៕



រូបភាពនៃកិច្ចប្រជុំស្តីពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា



## IV- សកម្មភាពដទៃទៀតរបស់ ឯកឧត្តម ទេសរដ្ឋមន្ត្រី យឹម ណុលឡា ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែមិថុនា ឆ្នាំ២០១៨

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០៣/០៦/១៨ ម៉ោង១៤:០០នាទី | ចូលរួមកិច្ចប្រជុំត្រួតពិនិត្យការអនុវត្តផែនការការងារគណបក្សដែលបានដាក់ចុះកន្លងមក ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន** សមាជិកគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា និងជាប្រធានក្រុមការងារថ្នាក់កណ្តាលចុះជួយខេត្តតាកែវ នៅមន្ទីរគណៈកម្មាធិការគណបក្សខេត្តតាកែវ។ |
| ២ | ០៤/០៦/១៨ ម៉ោង១៦:០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីបិទការប្រកួតកីឡាជាតិលើកទី២ ក្រោមប្រធានបទ "កីឡា ដើម្បីសន្តិភាព និងការអភិវឌ្ឍ" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅពហុកីឡដ្ឋានជាតិ (អូឡាំពិក)។ |
| ៣ | ០៥/០៦/១៨ ម៉ោង០៧:០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីបិទវគ្គប្រគល់សញ្ញាបត្រ វិញ្ញាបនបត្រ ជូនសិស្សមន្ត្រីជាន់ខ្ពស់ សិស្សមន្ត្រីក្រមការ កម្មសិក្សាការី ឆ្នាំ២០១៧ និងពិធីបើកវគ្គបណ្តុះបណ្តាល ឆ្នាំ២០១៨ របស់សាលាភូមិន្ទរដ្ឋបាល ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅវិទ្យាស្ថានជាតិអប់រំ។ |
| ៤ | ០៦/០៦/១៨ ម៉ោង០៨:០០នាទី | ចូលរួមជាគណៈអធិបតី ក្នុងពិធីសំណេះសំណាលជាមួយអាចារ្យ-អាចារិនីខ្មែរ ក្រោមអធិបតីភាព លោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច តំណាងដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅសាលសន្និសីទចតុមុខ។ |
| ៥ | ០៦/០៦/១៨ ម៉ោង១៥:៣០នាទី | ជួបប្រជុំពិភាក្សាការងារជាមួយឯកឧត្តម **កែវ រ៉េមី** នៅបន្ទប់ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៦ | ០៧/០៦/១៨ ម៉ោង១០:៣០នាទី | ជួបប្រជុំពិភាក្សាការងារជាមួយឯកឧត្តម **ផៃធ សុខដារ៉ានោ** នៅបន្ទប់ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៧ | ០៨/០៦/១៨ ម៉ោង០៩:៣០នាទី | ដឹកនាំកិច្ចប្រជុំក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានឃុំ០៦នៃស្រុកព្រៃកប្បាស ខេត្តតាកែវ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
| --- | --- | --- |
| ៨ | ១១/០៦/១៨ ម៉ោង០៩:៣០នាទី | ជួបប្រជុំពិភាក្សាការងារលើកទី១ ជាមួយលោកជំទាវ **តាល់ ណៃអ៊ីម** ឯកឧត្តម **អ៊ុច ថោងសេង** និងឯកឧត្តម **ផាត់ លេង** នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៩ | ១៥/០៦/១៨ ម៉ោង០៩:៣០នាទី | ជួបប្រជុំពិភាក្សាការងារលើកទី២ ជាមួយលោកជំទាវ **តាល់ ណៃអ៊ីម** ឯកឧត្តម **អ៊ុច ថោងសេង** ឯកឧត្តម **ផាត់ លេង** និងឯកឧត្តម **សំ សំណាង** នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១០ | ១៧/០៦/១៨ ម៉ោង០៧:៣០នាទី | ចូលរួមកិច្ចប្រជុំ បន្តត្រួតពិនិត្យការអនុវត្តផែនការការងារគណបក្សដែលបានដាក់ចុះកន្លងមក ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន** សមាជិកគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា និងជាប្រធានក្រុមការងារថ្នាក់កណ្តាលចុះជួយខេត្តតាកែវ នៅមន្ទីរគណៈកម្មាធិការគណបក្សខេត្តតាកែវ។ |
| ១១ | ១៩/០៦/១៨ ម៉ោង០៨:០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីប្រកាសគោរមងារវិទ្យាសាស្ត្រ គោរមងារកិត្តិយស និងការតែងតាំងសមាជិកពេញសិទ្ធិនៃរាជបណ្ឌិត្យសភាកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅវិមានសន្តិភាព។ |
| ១២ | ២០/០៦/១៨ ម៉ោង០៧:០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីសំណេះសំណាលជាមួយបងប្អូនកម្មករនិយោជិត នៅក្រុងដូនកែវ ខេត្តតាកែវ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅភូមិត្រពាំងអង្គ សង្កាត់រការក្រៅ ក្រុងដូនកែវ ខេត្តតាកែវ។ |
| ១៣ | ២១/០៦/១៨ ម៉ោង០៧:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីបើកវេទិកាវិទ្យាសាស្ត្រស្តីពី “ខួបលើកទី៦០ ទំនាក់ទំនងកម្ពុជា-ចិនៈជំនួបអ្នកវិទ្យាសាស្ត្រ” ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជារដ្ឋមន្ត្រីស្តីទីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅសណ្ឋាគារភ្នំពេញ។ |
| ១៤ | ២១/០៦/១៨ ម៉ោង១៤:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីបិទសន្និសីទអន្តរជាតិលើកទី២ស្តីពី “ការអនុវត្តកិច្ចព្រមព្រៀងទទួលស្គាល់គ្នាទៅវិញទៅមកលើអ្នកជំនាញទេសចរណ៍អាស៊ាន” ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅសណ្ឋាគារសុខាវ៉េស៊ីដង់ភ្នំពេញ។ |
| ១៥ | ២២/០៦/១៨ ម៉ោង០៧:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីប្រគល់សញ្ញាបត្រថ្នាក់បរិញ្ញាបត្រ និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជូនដល់និស្សិត នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ។ |

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
| --- | --- | --- |
| ១៦ | ២៣/០៦/១៨<br>ម៉ោង០៧:០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីសម្ពោធដាក់ឲ្យដំណើរការសួនសត្វ ភ្នំពេញ សាហ្វារី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅភូមិបាក់ខែងលើ សង្កាត់បាក់ខែង ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។ |
| ១៧ | ២៦/០៦/១៨<br>ម៉ោង០៩:៣០នាទី | ជួបប្រជុំពិភាក្សាការងារជាមួយឯកឧត្តម **ឆយ អូន** និងឯកឧត្តម **សំ សំណាង** នៅបន្ទប់ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៨ | ២៧/០៦/១៨<br>ម៉ោង១០:០០នាទី | ជួបប្រជុំពិភាក្សាការងារលើកទី៣ ជាមួយលោកជំទាវ **តាល់ ណៃអ៊ីម** ឯកឧត្តម **អ៊ុច ថោងសេង** ឯកឧត្តម **ផាត់ សេង** ឯកឧត្តម **សំ សំណាង** និងលោក **គង់ ថវៈ** នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៩ | ២៨/០៦/១៨<br>ម៉ោង០៨:៣០នាទី | ដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដើម្បីប្រជុំស្តីពីការវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ប្រចាំខែឧសភា ឆ្នាំ២០១៨ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២០ | ២៩/០៦/១៨<br>ម៉ោង០៧:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីបើកការដ្ឋានសាងសង់ស្ពានអាកាស និងផ្លូវក្រោមដី រង្វង់មូលចោមចៅ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅភូមិថ្នល់បំបែក សង្កាត់ចោមចៅទី៣ ខណ្ឌពោធិសែនជ័យ រាជធានីភ្នំពេញ។ |
| ២១ | ២៩/០៦/១៨<br>ម៉ោង១៥:៣០នាទី | ដឹកនាំកិច្ចប្រជុំ ស្តីពីសំណើសុំទទួលស្គាល់ការបង្កើតវិទ្យាស្ថានពាណិជ្ជសាស្ត្រ និងបច្ចេកវិទ្យាក្រុងព្រះសីហនុ នៅខេត្តព្រះសីហនុ ជាមួយក្រុមប្រឹក្សាអ្នកច្បាប់ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២២ | ៣០/០៦/១៨<br>ម៉ោង០៨:៣០នាទី | ចូលរួមជាអធិបតី ក្នុងពិធីសំណេះសំណាលជាមួយថ្នាក់ដឹកនាំគណបក្សមូលដ្ឋានក្នុងឃុំព្រៃល្វា និងមន្ត្រីរាជការ ០៦ឃុំ ក្នុងស្រុកព្រៃកប្បាស នៅវិទ្យាល័យហេងសំរិន ព្រៃល្វា ស្រុកព្រៃកប្បាស ខេត្តតាកែវ។ |

# ព្រឹត្តិបត្រព័ត៌មាន



## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌


ទូរស័ព្ទលេខ: ០២៣ ២១១ ៩៤៣ ០១៦ ៣០៧ ៣៣០

ទូរសារលេខ: ០២៣ ២១១ ៩៤៣

E-mail: veasna@live.in